ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ : ៨១៧ សស៍ណា.ប.ស្ថ

# សេចក្តីប្រកាសព័ត៌មាន
# វេទិកាកេសរកូលជាតិលើកទី២

ក្រសួងបរិស្ថាន មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជន និងបណ្តាញសារព័ត៌មានជាតិ និងអន្តរជាតិឱ្យបានជ្រាបថា ក្រសួងបរិស្ថាននឹងរៀបចំ **"វេទិកាកេសរកូលជាតិលើកទី២" នៅថ្ងៃពុធ ១២កើត ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២២ ចាប់ពីម៉ោង ០៨:៣០នាទី ដល់ម៉ោង ១៧:០០នាទី** នៅអគារខេមរានី សហភាពសហព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក.) រាជធានីភ្នំពេញ ក្រោមអធិបតីភាព **ឯកឧត្តម សាយ សំអាល់** រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (ក.ជ.អ.ច.) ដោយមានការអញ្ជើញចូលរួមពីតំណាងក្រសួង ស្ថាប័ន ស្ថានទូត អង្គការដៃគូ វិស័យឯកជន អ្នកជំនាញជាតិ និងអន្តរជាតិ សិស្ស និស្សិត និងអ្នកពាក់ព័ន្ធ។

វេទិកានេះរៀបចំឡើងក្នុងគោលបំណងដើម្បី៖ ១)ផ្សព្វផ្សាយឱ្យសាធារណជនបានស្គាល់ពីប្រភេទកេសរកូលព្រៃរបស់កម្ពុជា ២)ចែករំលែកព័ត៌មានស្តីពីវឌ្ឍនភាពនៃការរៀបចំមជ្ឈមណ្ឌលស្រាវជ្រាវ និងអភិរក្សកេសរកូល សុខ អាន ភ្នំគូលែន ៣)ចូលរួមចំណែកលើកកម្ពស់វិស័យទេសចរណ៍ធម្មជាតិ និង ៤)ផ្សារភ្ជាប់បណ្តាញអ្នកសិក្សាស្រាវជ្រាវ និងពង្រឹងការអភិរក្សកេសរកូលព្រៃនៅកម្ពុជា។

វេទិកានេះក៏មានការតាំងបង្ហាញពីប្រភេទកេសរកូលព្រៃ កេសរកូលពូជបង្កាត់ រុក្ខជាតិកម្រ រុក្ខជាតិលម្អ និងផលិតផលធម្មជាតិជាច្រើនប្រភេទ ដែលអនុញ្ញាតឱ្យសិស្ស និស្សិត ភ្ញៀវជាតិ-អន្តរជាតិ និងសាធារណជនអាចចូលទស្សនាដោយសេរី ចាប់ពីម៉ោង ១៣:៣០នាទី ដល់ម៉ោង ១៧:០០នាទី។

អាស្រ័យហេតុនេះ សូមអញ្ជើញសាធារណជន បណ្តាញសារព័ត៌មានជាតិ និងអន្តរជាតិ ចូលរួម និងផ្តិតយកព័ត៌មានក្នុងកម្មវិធីខាងលើ តាមការគួរ។

ថ្ងៃ អង្គារ ៣ កើត ខែ ពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ២០២២

ព័ត៌មានបន្ថែម សូមទាក់ទង៖
**ឯកឧត្តម នេត្រ ភក្ត្រា** រដ្ឋលេខាធិការ និង
ជាអ្នកនាំពាក្យក្រសួងបរិស្ថាន
លេខទូរសព្ទ៖ (៨៥៥) ១២ ៤៨៣ ២៨៣